**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦១ .អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ លើផ្ទៃដីសរុបចំនួន **៩.៤៧៧**(ប្រាំបួនពាន់ បួនរយ ចិតសិប ប្រាំពីរ)ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី សម្រាប់ផ្តល់ជូនក្រុមហ៊ុន MEGA FIRST CORPORATION BERHAD (MFCB) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម តំបន់អេកូទេសចរណ៍ និងតំបន់សេដ្ឋកិច្ចពិសេស រយៈពេល៩០ឆ្នាំ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ១៨៦ សជណ.កស ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១២ ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងដីវិនិយោគអភិវឌ្ឍន៍ របស់ក្រុមហ៊ុន MEGA FIRST CORPORATION BERHAD
ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំណាមលៀរ ឃុំសុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី លើផ្ទៃដីចំនួន ៩៤៧៧ ហិកតា






សញ្ញាសម្គាល់
- ចំណុចនិយាមការ
- ទីតាំងដីវិនិយោគ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង. អូរ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ

| ID | N | X | Y |
|---|---|---|---|
| 1 | A | 759853 | 1360046 |
| 2 | B | 755492 | 1364534 |
| 3 | C | 759001 | 1367344 |
| 4 | D | 762414 | 1367903 |
| 5 | E | 766237 | 1367685 |
| 6 | F | 766282 | 1363645 |
| 7 | G | 766329 | 1359412 |